# សេចក្តីថ្លែងការណ៍
# ពលករខ្មែរកំពុងជាប់នៅប្រទេសហ្ស៊កដានីត្រូវការជំនួយដើម្បីបានត្រឡប់មកប្រទេសកំណើតវិញ

**ថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០២០**

មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និង សិទ្ធិមនុស្ស **(សង់ត្រាល់)** សូមអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជាជួយអន្តរាគមន៍ភ្លាមៗដើម្បីសម្របសម្រួលឱ្យប្រជាពលរដ្ឋខ្មែរដែលកំពុងជាប់នៅប្រទេសហ្ស៊កដានី (Jordan) បានត្រឡប់មកប្រទេសកម្ពុជាវិញ ។ ក្រុមហ៊ុន Vega Textile Co., Ltd និង Camel Textile International Corporation គឺជារោងចក្រកាត់ដេរស្ថិតនៅទីក្រុងអាល់ការ៉ាក់ (Al-Karak) នៅប្រទេសហ្ស៊កដានី បានបញ្ចប់កិច្ចសន្យាការងារពលករខ្មែរយ៉ាងហោចណាស់សរុប ២១ នាក់កាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០ ។ យោងតាមកិច្ចសន្យាសម្រាប់ពលករចំណាកស្រុកក្នុងប្រទេសហ្ស៊កដានី និង កិច្ចព្រមព្រៀងដោយផ្ទាល់មាត់របស់ពលករជាមួយក្រុមហ៊ុនមុនពេលដែលពួកគាត់បានចេញដំណើរពីប្រទេសកម្ពុជា ក្រុមហ៊ុន Vega Textile និង Camel Textile ទទួលខុសត្រូវក្នុងការទិញសំបុត្រយន្តហោះឱ្យពួកគាត់ត្រឡប់មកប្រទេសកម្ពុជាវិញ នៅពេលដែលកិច្ចសន្យាការងាររបស់ពលករខ្មែរទាំងនេះត្រូវបានបញ្ចប់ ។ ប៉ុន្តែក្រុមហ៊ុន Vega Textile និង Camel Textile ខកខានមិនបានទិញសំបុត្រយន្តហោះ ព្រមទាំងមិនបានជូនដំណឹងដល់ពលករខ្មែរអំពីពេលវេលាដែលក្រុមហ៊ុនគ្រោងទិញសំបុត្រយន្តហោះនោះទេ ។ លើសពីនេះទៀត ក្រុមហ៊ុន Vega Textile និង Camel Textile មិនបានផ្តល់អត្ថប្រយោជន៍ផ្នែកគាំពារសង្គមដែលកន្លងមកក្រុមហ៊ុនបានកាត់ពីប្រាក់ឈ្នួលរបស់ពលករជារៀងរាល់ខែដែលអត្ថប្រយោជន៍ទាំងនោះយ៉ាងហោចណាស់ប្រមាណ ១០០០ ដុល្លារអាមេរិកសម្រាប់ពលករម្នាក់ៗ ។ ពលករខ្មែរទាំងនេះបានជាប់នៅប្រទេសហ្ស៊កដានីដោយគ្មានការងារធ្វើ នឹងបាត់បង់ប្រាក់ចំណូលអស់រយៈពេល ០៣ ខែមកហើយ ។

ក្រុមហ៊ុន Vega Textile និង Camel Textile មានក្រុមហ៊ុនមេដែលមានការិយាល័យកណ្តាលនៅប្រទេសតៃវ៉ាន់។ យោងតាមបញ្ជីព័ត៌មាន ក្រុមហ៊ុនមេនេះក្រៅពីធ្វើការបញ្ជាទិញពីរោងចក្រទាំងពីរខាងលើក៏មានរោងចក្រយ៉ាងហោចណាស់ ០២ ដែរនៅប្រទេសកម្ពុជារួមមាន ៖

១. រោងចក្រអុបធីមឹម ហ្វេសិន មេនូហ្វេកធឺរីង ឯ.ក (Optimum Fashion Manufacturing Co., Ltd.) មានអាសយដ្ឋាននៅភូមិព្រៃផ្តៅ ឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ។

២. រោងចក្រយូ អាយ ស៊ី អឺភែរ៉ឹល មេនូហ្វេកធឺរីង (U.I.C Apparel Manufacturing Co., Ltd.) មានអាស័យដ្ឋាននៅភូមិត្រពាំងទួល សង្កាត់កំបូល ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។

កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ រដ្ឋមន្ត្រីក្រសួងការងាររបស់ប្រទេសហ៊្សកដានី ឯកឧត្តម Nidal Bataineh បានចុះទៅពិនិត្យមើលដោយផ្ទាល់នូវស្ថានភាពរបស់កម្មករនិយោជិតនៅរោងចក្រ Vega Textile និង Camel Textile បន្ទាប់ពីកម្មករនិយោជិតបានប្តឹងទៅក្រសួងការងាររបស់ប្រទេសហ៊្សកដានី ។ យោងតាម សេចក្តីថ្លែងការណ៍ របស់ក្រសួងការងាររបស់ប្រទេសហ៊្សកដានី រដ្ឋមន្ត្រីបានបង្គាប់ឱ្យរោងចក្រ Vega Textile និង Camel Textile ចាត់វិធានការកែតម្រូវលក្ខខណ្ឌការងារ ហើយក៏បានបញ្ជាឱ្យអធិការការងារចុះទៅពិនិត្យមើលរោងចក្រនេះក្នុងរយៈពេល ២សប្តាហ៍ដើម្បីធានាថាក្រុមហ៊ុននេះអនុវត្តតាមច្បាប់ ។ បន្ទាប់ពីក្រុមហ៊ុនបានព្យាយាមរារាំងមិនឱ្យពលករខ្មែរជួបជាមួយមន្ត្រីរបស់ក្រសួងការងាររបស់ប្រទេសហ្សកដានីជាច្រើនលើកច្រើនសា ជាចុងក្រោយ ពលករខ្មែរបានជួប និងពិភាក្សាដោយផ្ទាល់ជាមួយមន្ត្រីរបស់ក្រសួងការងាររបស់ហ៊្សកដានីកាលពីថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០២០ ដោយបានលើកឡើងពីការទាមទាររបស់ពួកគាត់ក្នុងការត្រឡប់មកស្រុកកំណើតវិញ ហើយទាមទារអត្ថប្រយោជន៍ផ្នែកកិច្ចគាំពារសង្គមពីក្រុមហ៊ុន Vega Textile និង Camel Textile ។

យើងខ្ញុំទទួលស្គាល់ថាមានការរឹតត្បិតនៃការធ្វើដំណើរតាមផ្លូវអាកាស ដែលអាចជាមូលហេតុដែលធ្វើឲ្យពួកគាត់កំពុងជាប់គាំងនៅប្រទេសហ៊្សកដានី ហើយយើងក៏សង្កេតឃើញដែរថា បច្ចុប្បន្នមានការបើកជើងហោះហើរមួយចំនួនពីប្រទេសហ៊្សកដានីទៅកាន់ទីក្រុងឌូបៃ និង ប្រទេសហ្កាតា ។ អ្នកធ្វើដំណើរពីទីក្រុងឌូបៃ និង ប្រទេសហ្កាតាអាចធ្វើដំណើរទៅកាន់ប្រទេសកូរ៉េខាងត្បូង និងទីក្រុងហុងកុង បន្ទាប់មកអាចនឹងធ្វើដំណើរមកកាន់ទីក្រុងភ្នំពេញវិញបាន ។ យើងខ្ញុំក៏ដឹងផងដែរថាបច្ចុប្បន្ននេះ តម្លៃសំបុត្រយន្តហោះមានការកើនឡើងក្នុងកំឡុងពេលនៃការរាតត្បាតសកលកូវីដ-១៩ នេះ ប៉ុន្តែវាមិនមែនជាមូលហេតុដើម្បីទុកពលករខ្មែរចោលឲ្យនៅក្រៅប្រទេសដោយគ្មានការងារធ្វើ បាត់បង់ប្រាក់ចំណូលនោះទេ ។ ក្រុមហ៊ុន Vega Textile និង Camel Textile ត្រូវតែបំពេញតួនាទីរបស់ខ្លួនស្របតាមច្បាប់ ហើយរៀបចំឲ្យពលករខ្មែរបានត្រឡប់មកស្រុកកំណើតវិញឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ។

ជាមួយគ្នានេះដែរ ក្រុមហ៊ុន Vega Textile និង Camel Textile ក៏បានជួលពលករជនជាតិភូមាមួយចំនួនដែរ ។ កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០ ពលករជនជាតិភូមាទាំងនោះក៏បាននិយាយជាសាធារណៈអំពីបញ្ហាប្រឈម និងទុក្ខលំបាករបស់ពួកគាត់នៅប្រទេសហ៊្សកដានីតាមរយៈ បទសម្ភាសន៍ជាមួយប្រព័ន្ធផ្សព្វផ្សាយ ។ ក្រោយពីមានការលើកឡើងរបស់ពលករជនជាតិភូមា កាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០ ស្ថានទូតសាធារណរដ្ឋមីយ៉ាន់ម៉ាប្រចាំប្រទេសអ៊ីស្រាអែលបានចេញសេចក្តីជូនដំណឹងស្តីពីការរៀបចំជើងហោះហើរធ្វើមាតុភូមិនិវត្តន៍សម្រាប់ប្រជាពលរដ្ឋភូមាដែលធ្វើការនៅរោងចក្រមួយចំនួននៅប្រទេសហ៊្សកដានីរួមទាំងក្រុមហ៊ុន Vega Textile និង Camel Textile ផងដែរ ។

លោក **មឿន តុលា** នាយកប្រតិបត្តិការនៃអង្គការសង់ត្រាល់បានលើកឡើងថា ៖ *"អន្តរាគមន៍ភ្លាមៗរបស់រដ្ឋាភិបាលភូមាគួរត្រូវបានសាទរក្នុងការជួយសង្គ្រោះប្រជាពលរដ្ឋខ្លួនដែលជាប់នៅក្រៅប្រទេស ។ ចំពោះករណីនេះ រាជរដ្ឋាភិបាលកម្ពុជាគួរតែអនុវត្តន៍ដូចរដ្ឋាភិបាលភូមាដែរ ហើយធ្វើទំនាក់ទំនងជាមួយក្រុមហ៊ុនអាកាសចរណ៍ដើម្បីរៀបចំឱ្យប្រជាពលរដ្ឋខ្មែរដែលជាប់នៅប្រទេសហ្ស៊ីរកដានីដោយគ្មានការងារធ្វើ បាត់បង់ប្រាក់ចំណូលបានត្រឡប់មកប្រទេសកម្ពុជាវិញ ដូចករណីដែលរាជរដ្ឋាភិបាលបានធ្វើនាពេលកន្លងមកសម្រាប់ករណីប្រជាពលរដ្ឋខ្មែរដែលជាប់គាំងនៅប្រទេសម៉ាឡេស៊ីនោះផងដែរ ។"*

អង្គការសង់ត្រាល់ អំពាវនាវសូមឱ្យរាជរដ្ឋាភិបាលកម្ពុជា ជាពិសេសក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ តាមរយៈស្ថានទូតរបស់ប្រទេសកម្ពុជាប្រចាំនៅប្រទេសអេហ្ស៊ីប និង គុយវ៉ែត ធ្វើអន្តរាគមន៍ភ្លាមៗលើករណីនេះដើម្បីធានាថាក្រុមហ៊ុន Vega Textile និង Camel Textile បំពេញតួនាទីរបស់ខ្លួន ជាពិសេសក្នុងការធ្វើមាតុភូមិនិវត្តន៍ប្រជាពលករខ្មែរ និងការទូទាត់អត្ថប្រយោជន៍ផ្នែកកិច្ចគាំពារសង្គមជូនពួកគាត់អោយបានគ្រប់គ្រាន់ ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងទៅ ៖
លោក **យុន ថារ៉ូ** អ្នកគ្រប់គ្រងកម្មវិធីការងារនៃអង្គការ (សង់ត្រាល់) ៖ ទូរស័ព្ទលេខ ០៩៣ ៥៥៦ ៦៧១